# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### ក្រុមហ៊ុន ផាក ហេនប៉ែក (ខេមប៊ូឌា) ឯ.ក

កិច្ចព្រមព្រៀង

រវាង

ក្រុមហ៊ុន ផាក ហេនប៉ែក (ខេមបូឌា) ឯ.ក ជាមួយតំណាងកម្មករ និង សហជីព
ប្រចាំក្រុមហ៊ុន

ឆ្នាំពីរពាន់ម្ភៃបី ខែមីនាថ្ងៃទី ១០វេលាម៉ោង ១ និង ០០នាទី ថ្ងៃត្រង់នៅការិយាល័យក្រុមហ៊ុន ផាកហេនប៉ែក (ខេមបូឌា) ឯ.ក មានកិច្ចប្រជុំពិភាក្សារវាងតំណាងក្រុមហ៊ុនប្រតិភូបុគ្គលិកនិងថ្នាក់ដឹកនាំសហជីពអភិវឌ្ឍន៍ចលនាការងារកម្ពុជាប្រចាំរោងចក្រ។ ក្រោយបានប្រជុំពិភាក្សាភាគីទាំងពីរបានយល់ព្រមព្រៀងគ្នាដូចខាងក្រោម៖

១-ភាគីទាំងពីរយល់ព្រមព្យួរការងាររយៈពេល២៣ថ្ងៃចំពោះកម្មករនិយោជិត២៦៦៥នាក់ មានផ្នែកដេរ ផ្នែកបិទការ ផ្នែកពិនិត្យគុណភាពផ្នែករេចខ្ចប់ ផ្នែកតុកាត់ ផ្នែកការិយាល័យផ្នែកឃ្លាំងផ្នែកជាងភ្លើងផ្នែកជាងម៉ាស៊ីនផ្នែកសន្តិសុខ ផ្នែកអនាម័យ ដោយគិតចាប់ពីរថ្ងៃទី១១ខែមីនាឆ្នាំ២០២៣ រហូតដល់ថ្ងៃទី០២ខែមេសា ឆ្នាំ២០២៣ ដោយសារគ្មានការបញ្ជាទិញ។

២-ភាគីកម្មករនិយោកជិតយល់ព្រមទទួលប្រាក់ឧបត្ថម្ភ ៥០ដុល្លាអាមេរិក ពីភាគីនិយោជក ដូច្នេះជាសរុបកម្មករនិយោជិតម្នាក់ទទួលបាន៥០ដុល្លារ អាមេរិកក្នុង១ខែសំរាប់រយៈពេលព្យួរការងារនេះ។

៣-ក្រុមហ៊ុននិងបើកជូនប្រាក់ឧបត្ថម្ភ៥០ដុល្លាអាមេរិកនេះជូនកម្មករនិយោជិត១ខែម្តង។

៤-បងប្អូនត្រូវត្រលប់ចូលមកធ្វើការវិញនាថ្ងៃទី០៣ ខែមេសា ឆ្នាំ ២០២៣ ក្នុងករណីបងប្អូន កម្មករមិនបាន ចូលធ្វើការតាមការកំណត់នេះទេ ក្រុមហ៊ុននឹងអនុវត្តន៍តាមច្បាប់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន។

កិច្ចព្រមព្រៀងនេះ ចាប់អនុវត្តន៍និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

កំពង់ស្ពឺ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២៣

តំណាងក្រុមហ៊ុន

ស្នាមមេដៃតំណាងកម្មករនិយោជិត

១..........

២..........

៣..........

៤..........

៥..........

៦..........

៧..........